នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់ : ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា
ភាសាដើម : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Jan-2015, 12:06
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:
ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:
ឈ្មោះមន្ត្រីដែលបានពិនិត្យ:
ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ នួន ជា ទាក់ទងនឹងការអនុវត្ត មួយចំនួនដែលត្រូវប្រើនៅពេលសួរសាក្សីដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 និង អ្នកដទៃទៀតក្នុងសំណុំរឿង០០២/០២ នាពេលខាងមុខ និងដើមបណ្តឹងរដ្ឋប្បវេណីទូទៅ**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Claudia FENZ
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
ជនជាប់ចោទ
នួន ជា
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

## I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

1. នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ នួន ជា បានដាក់ញត្តិមួយជំទាស់ទៅនឹងការអនុវត្តនៅក្នុងសំណុំរឿង០០២/០២ លើការអនុវត្តចំនួនបី ដែលបានអនុវត្តនៅក្នុងសំណុំរឿង០០២/០១ រួមមាន (i) ការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការអនុញ្ញាតឱ្យសាក្សីពិនិត្យឡើងវិញនូវកំណត់ហេតុស្តាប់ចម្លើយពីមុនៗរបស់ខ្លួនមុននឹងផ្តល់សក្ខីកម្ម និងអនុញ្ញាតឱ្យសួរសាក្សីនូវសំនួរនាំមុខ ដែលមានមូលដ្ឋាននៅលើកំណត់ហេតុស្តាប់ចម្លើយនោះ (ii) ការកម្រិតមិនត្រឹមត្រូវទៅលើវិសាលភាពនៃការសួរដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") ចំពោះសាក្សីរបស់ភាគីបដិបក្ខ និង (iii) ការទុកចិត្តទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី[1]។ មេធាវីការពារក្តីបានយោងទៅដល់បណ្តឹងសាទុក្ខ ដែលខ្លួនបានដាក់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង០០២/០១ ដោយបានដាក់បញ្ចូលទៅក្នុងសំណើ *ទៅតាមការចាំបាច់* នូវសំណើរបស់ខ្លួនទាក់ទងនឹងបញ្ហាដូចគ្នាបេះបិទ[2]។ មេធាវីការពារក្តីស្នើសុំថា សំណើនេះត្រូវធ្វើការដោះស្រាយជាការប្រញាប់ ដោយសារតែភស្តុតាងដែលនឹងមាននាពេលខាងមុខនេះនឹងត្រូវបានផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 និងដោយសារតែផលប៉ះពាល់នៃការអនុវត្តនានាក្នុងសំណុំរឿង០០២/០១ ទៅលើរបៀបដែលដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវផ្តល់សក្ខីកម្ម[3]។

2. នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") ជាទូទៅ៖ (i) ហាមឃាត់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយក្នុងសំណុំរឿង០០២/០២ កុំឱ្យពិនិត្យមើលកំណត់ហេតុស្តាប់ចម្លើយពីមុនៗរបស់ខ្លួនមុននឹងផ្តល់សក្ខីកម្ម (ii) ហាមឃាត់ភាគីនានាកុំឱ្យសួរសំនួរនាំមុខដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃកំណត់ហេតុស្តាប់ចម្លើយពីមុនៗរបស់ពួកគាត់ (iii) អនុញ្ញាតដល់មេធាវីការពារក្តីនូវ "ចន្លោះពេល" ដើម្បីសួរដេញដោលលើសច្ចភាពរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ នៅពេលសួរដេញដោលសាក្សីរបស់ភាគីបដិបក្ខ ដោយរួមទាំងថ្វីដែលទាក់ទងនឹងភាពជឿជាក់បាន និងភាពគួរឱ្យទុកចិត្ត និង (iv) តម្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយណាដែលត្រូវកោះហៅឱ្យមកផ្តល់ភស្តុតាងនៅក្នុងសំណុំរឿង០០២/០២ ចំពោះអង្គហេតុក្រៅពីផល

---

[1] **E336** សំណើរបស់ នួន ជា ពាក់ព័ន្ធនឹងកាអនុវត្តមួយចំនួនដែលត្រូវមាន នៅពេលសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 2-TCCP-271 នាពេលខាងមុខ និងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗទៀតក្នុងសំណុំរឿង០០២/០២ ជាទូទៅ, ១៦ មករា ២០១៥ ("សំណើ")។ នួន ជា បានដាក់សំណើនេះដោយត្រូវបានបង្គាប់ដោយអង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ដែលបង្គាប់ឱ្យដាក់ការជំទាស់ ផ្ទាល់មាត់ដែលគាត់បានលើកឡើងនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជាលាយលក្ខអក្សរវិញ។ *សូមអាន* ប្រតិចារឹក, ៨ មករា ២០១៥, ទំព័រទី ៣៣-៣៤។

[2] *ដដែលដូចមុន* ។ កថាខណ្ឌទី៥, ដោយបានយោងទៅឯកសារលេខ **F16** អង្គភាពគាំពារការការពាក្តី ស្នើរសុំអង្គជំនុំជម្រះតុលាការកំពូលអនុវត្តអំណាចរបស់ខ្លួន ក្រោមវិធាន ៣៣ នៃវិធានផ្ទៃក្នុងរបស់ អវតក, ២៩ ធ្នូ ២០១៤ ("បណ្តឹងសាទុក្ខ"), កថាខណ្ឌទី ១៣៥-១៥៣, ១៨៧-១៩៣។

[3] *ដដែលដូចមុន* ។ កថាខណ្ឌទី៣, ១៧-១៩។

ប៉ះពាល់ ឬសំណាងនោះ ត្រូវធ្វើសម្បថមុនពេលផ្តល់សក្ខីកម្ម[4]។ បន្ថែមទៀត នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះ៖ (i) តម្រូវឱ្យ 2-TCCP-271 ផ្តល់សក្ខីកម្មនៅក្រោម សម្បថ (ii) ហាមឃាត់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 ក្នុងការពិនិត្យឡើងវិញនូវកំណត់ហេតុស្តាប់ចម្លើយពីមុនៗមុននឹងផ្តល់សក្ខីកម្ម និង (iii) អនុញ្ញាតដល់មេធាវីការពារក្តីនូវ "ចន្លោះពេល" ដើម្បីសួរដេញដោលលើសច្ចភាពនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 នៅពេលសួរដេញដោលសាក្សីរបស់ភាគីបដិបក្ខ[5]។

3. ចំពោះហេតុផលទាំងឡាយដូចបានថ្លែងនៅខាងក្រោមនេះ សហព្រះរាជអាជ្ញា ជូនសេចក្តីសន្និដ្ឋានថា សំណើនោះគួរត្រូវបានបដិសេធចោល។

## II. អំណះអំណាង

4. សហព្រះរាជអាជ្ញា កត់សំគាល់តាំងពីដំបូងថា អង្គជំនុំជម្រះបានពិចារណា និងបានសម្រេចរួចហើយក្នុងសំណុំរឿង០០២/០១ ទាក់ទងនឹង៖ (i) សាក្សីដែលបានទទួលកំណត់ហេតុស្តាប់ចម្លើយពីមុនៗរបស់ពួកគាត់ មុននឹងផ្តល់សក្ខីកម្ម[6] (ii) សំនួរនាំមុខដែលសួរក្នុងន័យដេញដោលទៅរកកំណត់ហេតុស្តាប់ចម្លើយមុនៗ[7] និង (iii) ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវផ្តល់សក្ខីកម្មដោយមិនចាំបាច់ធ្វើសម្បថ[8]។ នួន ជា បានប្តឹងឧទ្ធរណ៍លើបញ្ហានេះទៅអង្គជំនុំជម្រះតុលាការ

---

[4] សំណើ, កថាខណ្ឌទី២០។

[5] *ដដែលដូចមុន*។

[6] សូមមើល *ឧទាហរណ៍* **E141** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ "ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១", ១៧ វិច្ឆិកា ២០១១ [កថាខណ្ឌ ដែលមានចំណងជើងថា "ការត្រៀមរៀបចំសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ"]។ **E141/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា៖ "ការប្រគល់ចម្លើយមុនៗឱ្យសាក្សីមុនពេលសាក្សីធ្វើសក្ខីកម្មនៅសវនាការ", ២៤ វិច្ឆិកា ២០១១។ **E292/2/1** សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងកុំផ្តល់កំណត់ហេតុនៃការស្តាប់ចម្លើយលើកមុន ទាក់ទងនឹងទួលពោធិ៍ជ្រៃ ដល់សាក្សីនៅមុនការផ្តល់សក្ខីកម្ម (ឯកសារ E292/2), ២៧ មិថុនា ២០១៣។

[7] **E201/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងជូនចំពោះភាគី មានចំណងជើងថា "សេចក្តីជូនដំណឹងទៅភាគីពាក់ព័ន្ធនឹងនីតិវិធីនៃការកែសម្រួលការសួរសំណួរនិងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ឯកសារនានាក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សី, ១៣ មិថុនា ២០១២។

[8] សូមមើល *ជាឧទាហរណ៍* ឯកសារលេខ **E74** អនុស្សរណៈជូនភាគី "ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១"។ **E141** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ "ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១១", ១៧ វិច្ឆិកា ២០១១។ **E141/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "ការប្រគល់ចម្លើយមុនៗឱ្យសាក្សីមុនពេលសាក្សីធ្វើសក្ខីកម្មនៅសវនាការ", ១៤ វិច្ឆិកា ២០១១។ **E267/3** សេចក្តីសម្រេចលើសំណើសុំកោះហៅសាជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 និងសុំឱ្យពិនិត្យឡើងវិញលើ

កំពូល ក្រោយការចេញសាលក្រមរបស់សាលាដំបូងក្នុងសំណុំរឿង០០២/១[9] ហើយសហព្រះរាជអាជ្ញា មានបំណងចង់ឆ្លើយតបលម្អិត តាមរយៈការដាក់ឯកសារមួយនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ សហព្រះរាជអាជ្ញា ជូនសេចក្តីសន្និដ្ឋានថា រហូតដល់ពេលដែលអង្គជំនុំជម្រះតុលាការកំពូលសម្រេចលើបញ្ហាទាំងនេះ នោះការអនុវត្តក្នុងសំណុំរឿង០០២/០១ ដែល នួន ជា ជំទាស់នោះ គឺនៅតែអនុវត្តបានចំពោះសំណុំរឿង០០២/០២ រួមទាំងចំពោះសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 ផងដែរ។

5. សហព្រះរាជអាជ្ញាធ្វើការសង្កេតបន្ថែមទៀតថា មេធាវីការពារក្តីបាននិយាយខុសអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សីពីមុន។ ផ្ទុយទៅនឹងញត្តិស្នើសុំរបស់មេធាវីការពារក្តី អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យសហព្រះរាជអាជ្ញា "សួរដេញដោលសាក្សីតាមរយៈការអានជូនសាក្សី អំពីខ្លឹមសារក្នុងផ្នែកនៃកំណត់ហេតុទាំងនេះ ដើម្បីស្វែងរកការបញ្ជាក់អះអាងចំពោះភាពត្រឹមត្រូវនោះទេ"[10]។ នីតិវិធីដែលមានស្រាប់ទាក់ទិននឹងការប្រើប្រាស់កំណត់ហេតុពីមុន ត្រូវអង្គជំនុំជម្រះថ្លែងយ៉ាងដូច្នេះ ៖

> "អង្គជំនុំជម្រះសាលាដំបូងសូមរំលឹកភាគីថា ដើម្បីផលប្រយោជន៍នៃការធានាបាននូវភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីនោះ នាពេលថ្មីៗនេះ អង្គជំនុំជម្រះបានចាប់ផ្តើមសួរសំនួរទៅសាក្សីម្នាក់ៗដែលមកផ្តល់សក្ខីកម្មថា តើសាក្សីបានពិនិត្យមើលឡើងវិញនូវចម្លើយដែលខ្លួនបានផ្តល់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) ដែរឬទេ ហើយថាតើចម្លើយទាំងនេះជាចម្លើយត្រឹមត្រូវដែលសាក្សីបានឆ្លើយនៅដំណាក់កាលស៊ើបអង្កេត មែនឬយ៉ាងណា។ ក្នុងករណីដែលសាក្សីគូសបញ្ជាក់ថា ខ្លួនពិតជាចាំចម្លើយរបស់ខ្លួន ហើយខ្លឹមសារនៃចម្លើយដូចដែលបានកត់ត្រានៅក្នុងកំណត់ហេតុជាលាយល័ក្ខណ៍អក្សរ ក.ស.ច.ស មានភាពត្រឹមត្រូវ ភាគីមិនត្រូវស្នើផ្ទួនៗសុំឱ្យសាក្សីបញ្ជាក់អំពីការពិត

បែបបទ ពាក់ព័ន្ធនឹងសក្ខីកម្មស្តីពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសំណើ និងចម្លើយតបនានាដែលពាក់ព័ន្ធ (E240, E240/1, E250, E250/1, E267, E267/1 និង E267/2), ២ ឧសភា ២០១៣។ **E292/2/1** "សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងកុំផ្តល់កំណត់ហេតុនៃការស្តាប់ចម្លើយលើកមុនទាក់ទងនឹងទួលពោធិ៍ជ្រៃ ដល់សាក្សីនៅមុនការផ្តល់សក្ខីកម្ម(ឯកសារ E292/2), ២៧ មិថុនា ២០១៣។ សូមមើលផងដែរ **E1/17.1** ប្រតិចារឹក ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១, ត្រង់ទំព័រ៣៤-៣៥។ E1/164.1 ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣, ត្រង់ទំព័រ៧៦។ **E1/2.1** ប្រតិចារឹក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១, ត្រង់ទំព័រ១០០។ **E188** សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *កាំង ហ្គេចអ៊ាវ*, ២៦ កក្កដា ២០១០, កថាខណ្ឌ៥២-៥៣។ សហព្រះរាជអាជ្ញាសូមយោងសេចក្តីសន្និដ្ឋានពីមុនរបស់ខ្លួនក្នុងសំណុំរឿង០០២/០១ ទាក់ទងនឹងបញ្ហាទាំងនេះ។ សូមមើល អនុស្សរណៈពីសហព្រះរាជអាជ្ញា មាននចំណងជើងថា "បញ្ហាដែលត្រូវលើកនៅមុនពេលសវនាការ", ១ វិច្ឆិកា ២០១១, កថាខណ្ឌ៣។ **E267** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្របតាមវិធាន៩២ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី, ២១ កុម្ភៈ ២០១៣, កថាខណ្ឌ១១-២២។

[9] សូមមើល បណ្តឹងសាទុក្ខ, កថាខណ្ឌ 135-153, 187-193។ សូមមើលផងដែរ ឯកសារ **E313** សូមមើល បណ្តឹងសាទុក្ខ, សាលក្រមសំណុំរឿង០០២/០១, ៧ សីហា ២០១៤។

[10] សំណើ, កថាខណ្ឌ៦។

នេះ ឬព្យាយាមបង្ខំសាក្សីឲ្យរៀបរាប់ឡើងវិញអំពីខ្លឹមសារនៃចម្លើយនោះឡើយ។ ជំនួសមកវិញ ភាគីគួរតែប្បីផ្តោតការខិតខំរបស់ខ្លួនលើសំនួរផ្សេងៗ (ឧទាហរណ៍ សំនួរស្តីពីបញ្ហានានាដែលពុំស្ថិតនៅក្នុងខ្លឹមសារនៃចម្លើយ) ឬការជំទាស់តវ៉ាជាក់លាក់ទៅនឹងភាពអាចជឿជាក់បាននៃចម្លើយ ឬភស្តុតាងរបស់សាក្សី”[11]។

6. ទាក់ទងទៅនឹងបញ្ហាដែលគេហៅថា “ការសួរសាក្សីរបស់ភាគីបដិបក្ខ” មេធាវីការពារក្តី ជាថ្មីម្តងទៀត បានដាក់បញ្ចូលអំណះអំណាងដែលពុំមានខ្លឹមសារ ពុំមានអង្គសេចក្តី ដកចេញពីសារណាបណ្តឹងសាទុក្ខរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១ ហើយខកខានមិនបានធ្វើការបង្ហាញអ្វីមួយទាល់តែសោះថា អង្គជំនុំជម្រះ បានរារាំង ឬបានដាក់កំរិតហួសហេតុទៅលើលទ្ធភាពរបស់មេធាវីការពារក្តី ក្នុងការសួរដេញដោលសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០២/០២[12]។ ដូចជាករណីនៅទូទាំងសវនាការលើសំណុំរឿង ០០២/០១ គេបានផ្តល់ឱកាសសមស្របមួយឲ្យទៅមេធាវីការពារក្តី ដើម្បីសួរដេញដោលសាក្សីនានា និងជំទាស់តវ៉ាលើភស្តុតាងរបស់ពួកគាត់ ដោយអនុលោមតាមវិធាន និងការអនុវត្តទាំងឡាយរបស់តុលាការនេះ ហើយពុំចាំបាច់មានដំណោះស្រាយ ឬសេចក្តីសម្រេចជាក់លាក់ណាមួយឡើយនៅទីនេះ។

7. ស្រដៀងគ្នានេះ នួន ជា យោងទៅរកតែកំហុសរបស់អង្គជំនុំជម្រះដែលខ្លួនចោទប្រកាន់ដោយពឹងផ្អែកទាំងស្រុងលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើជាសំអាងក្នុងសេចក្តីសម្រេចក្នុងសាលក្រមប៉ុណ្ណោះ ដោយពុំមានការបង្ហាញពីវិការៈណាមួយនៅក្នុងរបៀបដែលអង្គជំនុំជម្រះសាលាដំបូង មានចំពោះភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២/០២[13] ឡើយ។ សហព្រះរាជអាជ្ញា សង្កេតឃើញថា សារណារបស់ខ្លួន ដោយអនុលោមតាមវិធាន៩២ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការប្រើប្រាស់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺមិនត្រូវបានជំទាស់ដោយមេធាវីការពារក្តី នួន ជា ទេ។ ទម្ងន់ទាំងមូល និងតម្លៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានជាប់ជាមួយ គឺជាបញ្ហាមួយដែលអង្គជំនុំជម្រះនេះត្រូវធ្វើការកំណត់នៅពេលបញ្ចប់សវនាការ ដោយស្របទៅតាមភស្តុតាងទាំងអស់ដែលមានក្នុងកំណត់ហេតុ។ អំណះអំណាងណាដែលផ្ទុយពីនេះ គួរត្រូវបានបដិសេធចោល។

[11] **E201/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងជូនចំពោះភាគី មានចំណងជើងថា “សេចក្តីជូនដំណឹងទៅភាគីពាក់ព័ន្ធនឹងនីតិវិធីនៃការកែសម្រួលការសួរសំណួរនិងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ឯកសារនានាក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សី, ១៣ មិថុនា ២០១២។

[12] សូមមើល សំណើសុំ កថាខណ្ឌ៩-១០។

[13] សូមមើល សំណើសុំ កថាខណ្ឌ៩-១៥។

### III. ដំណោះស្រាយដែលស្នើឡើង

8. អាស្រ័យមូលហេតុដូចបានជំរាបជូនខាងលើ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើសុំនេះគួរត្រូវបានបដិសេធចោល ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | |